ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ :៣៨០

ចុះថ្ងៃទី២២-០៤-២០១៤

សាលដីកា

លេខ : ៧៣ក្រIV “វ”

ចុះថ្ងៃទី ១៨-០៨-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ដោយមាន ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ : ៣៨០ ចុះថ្ងៃទី២២-០៤-២០១៤ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] ទី ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ ទីកន្លែងកំណើតនៅ[redacted] ទីលំនៅបច្ចុប្បន្ន[redacted] ឪពុកឈ្មោះ [redacted] “វ” ម្តាយឈ្មោះ[redacted] “វ” ប្រពន្ធឈ្មោះ [redacted] “វ” មានកូន០១នាក់ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៩ ទោសពីមុនគ្មាន ។

-ចាប់ខ្លួនថ្ងៃទី២៦-០២-២០១៣ និងឃុំខ្លួន ថ្ងៃទី០១-០៣-២០១៤ ។/

២-ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករធ្វើនំ ទីកន្លែងកំណើតនៅភូមិ [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០១នាក់ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៧ ធ្លាប់ជាប់ពន្ធនាគាររយៈពេលពីរខែ ពីបទៈ ទទួលផលចោរកម្ម ។

-ចាប់ខ្លួនថ្ងៃទី២៦-០២-២០១៣ និងឃុំខ្លួនថ្ងៃទី០១-០៣-២០១៣ ។

៣-ជនជាប់ចោទឈ្មោះ [redacted] វតនា ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងផ្សារដែក ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០២នាក់ កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៧ ទោសពីមុនគ្មាន ។

-ចាប់ខ្លួនថ្ងៃទី២៦-០២-២០១៣ និងឃុំខ្លួនថ្ងៃទី០១-០៣-២០១៣ ។

<u>ជាប់ចោទពីបទៈ</u> លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្ទឹងខៀវ ភូមិ [redacted] កាលពីថ្ងៃទី២៦-០២-២០១៣ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីនាក់ ។

១-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ១៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបណ្ដោះអាសន្ន [redacted] ។

<u>ឯរឿងហេតុមានដូចតទៅ</u> ៖

កាលពីថ្ងៃទី២៦-០២-២០១៣ ឈ្មោះ [redacted] ចំណាប់ ភេទប្រុស, ឈ្មោះ [redacted] ទី ភេទប្រុស និងឈ្មោះ [redacted] វតនា ភេទប្រុស បាននាំគ្នាចូលដេកផ្ទះសំណាក់ស្ទឹងខៀវ ក្រុងបាត់ដំបង ហើយម្ចាស់ផ្ទះបានហៅឈ្មោះ [redacted] កញ្ញា ដែលជាស្ត្រីរកស៊ីផ្លូវភេទមកដេកជាមួយជនទាំងបីខាងលើ ។ លុះដល់ពេលរួមភេទរួចហើយ ជនល្មើសទាំងបីនាក់នេះ បានវាយនារីរងគ្រោះឈ្មោះ [redacted] កញ្ញា យកទ្រព្យសម្បត្តិតែម្ដង ។

រឿងនេះត្រូវបានសាលាដំបូងខេត្តបាត់ដំបង បានវិនិច្ឆ័យសេចក្ដីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ១០៣ "ឃ" ចុះថ្ងៃទី១៦-០១-២០១៤ ដែលមានខ្លឹមសារសម្រេចសេចក្ដីដូចខាងក្រោម៖

៣៦៤

១.ឱ្យឈ្មោះ [redacted] ទី បានរួចខ្លួនពីបទចោទ ពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ [redacted] កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៣ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោសចំពោះ៖

ក-ឈ្មោះ [redacted] ចំណាប់ ភេទប្រុស អាយុ២៦ឆ្នាំ

ខ-ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២៣ឆ្នាំ

ម្នាក់ៗដាក់ពន្ធនាគារកំណត់រយៈពេល០៣ឆ្នាំ (បីឆ្នាំ) ពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្ទឹងខៀវ ភូមិរំចេក៣ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] ចំណាប់ និងឈ្មោះ [redacted] រតនា រួមគ្នាសងសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ២,000,000៛ (ពីរលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

៤.លើកចោលបណ្តឹងទាមទារឱ្យសងការខូចខាត និងជំងឺចិត្តរបស់ដើមបណ្តឹងឈ្មោះ [redacted] ជាអសារបង់ ។

សាលក្រមនេះជុំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦-០១-២០១៤ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦-០៧-២០១៤ ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលា[redacted]ឧទ្ធរណ៍ ចុះថ្ងៃទី ១៥-០៨-២០១៤ ។

បានឃើញពាក្យស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] រតនា លើសាលក្រមព្រហ្មទណ្ឌលេខ: ១០៣ "ឈ" ចុះថ្ងៃទី១៦-០១-២០១៤ របស់សាលាដំបូងបាត់ដំបង ។

បានឃើញ ពាក្យស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ លើសាលក្រមព្រហ្មទណ្ឌលេខ: ១០៣ "ឈ" ចុះថ្ងៃទី១៦-០១-២០១៤ របស់សាលាដំបូងបាត់ដំបង ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

៣៦៨

-តំណាងមហាអយ្យការសន្និដ្ឋានៈសុំឱ្យក្រុមប្រឹក្សាចំណាយរឿងចេញពីបញ្ជីរបស់សាលាឧទ្ធរណ៍ ។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

យល់ឃើញថា

១- ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ និង [redacted] វគនា ប្តឹងនឹងសាលក្រមព្រហ្មទណ្ឌលេខ: ១០៣ "ឈ" ចុះថ្ងៃទី១៦-០១-២០១៤ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះ ដើម្បីជំនុំជម្រះដោយយោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ពាក្យស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] វគនា លើសាលក្រមព្រហ្មទណ្ឌលេខ: ១០៣ "ឈ" ចុះថ្ងៃទី១៦-០១-២០១៤ របស់សាលាដំបូងបាត់ដំបង ធ្វើឡើងក្នុងកំណត់ច្បាប់។

- ពាក្យស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ លើសាលក្រមព្រហ្មទណ្ឌលេខ: ១០៣ "ឈ" ចុះថ្ងៃទី១៦-០១-២០១៤ របស់សាលាដំបូងបាត់ដំបង ធ្វើឡើងក្នុងកំណត់ច្បាប់។

៣- តំណាងមហាអយ្យការសន្និដ្ឋានថា៖ ក្នុងរឿងនេះដោយសារជនជាប់ចោទឈ្មោះ [redacted] វគនា និងឈ្មោះ [redacted] ចំណាប់ បានស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍ហើយ តំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨០ ចុះថ្ងៃទី២២-០៤-២០១៤ ចេញពីបញ្ជី មានលក្ខណៈត្រឹមត្រូវ គប្បីក្រុមប្រឹក្សាពិចារណា ។

៤- ជនជាប់ចោទឈ្មោះ [redacted] វគនា និងឈ្មោះ [redacted] ចំណាប់ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ១០៣ "ឈ" ចុះថ្ងៃទី២២-០៤-២០១៤ តែក្រោយមកជនជាប់ចោទទាំងពីរ បានដាក់ពាក្យស្នើសុំដកពាក្យបណ្តឹងឧទ្ធរណ៍វិញ ដោយខ្លួនបានជាប់ឃុំក្នុងពន្ធនាគារមួយរយៈមកនេះ ខ្លួនទទួលស្គាល់កំហុស ដែលខ្លួនបានប្រព្រឹត្តក្នុងសង្គមកន្លងមក ទើបខ្លួនសម្រេចចិត្តសុំដកពាក្យបណ្តឹងឧទ្ធរណ៍ ដើម្បីសុំសាលក្រមព្រហ្មទណ្ឌស្ពាពរពីសាលាដំបូងខេត្តបាត់ដំបងមកអនុវត្ត ដូច្នេះគប្បីក្រុមប្រឹក្សាពិចារណា ចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ៣៨០ ចុះថ្ងៃទី២២-០៤-២០១៤ ចេញពីបញ្ជី តាមពាក្យស្នើសុំដកពាក្យបណ្តឹងចុះថ្ងៃទី២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ និងពាក្យស្នើសុំដកពាក្យបណ្តឹងចុះថ្ងៃទី២៤-០៧-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] វគនា ។

៣៧៤០

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨០ ចុះថ្ងៃទី២២-០៤-២០១៤ ចេញពីបញ្ជីតាមការដក ពាក្យបណ្តឹងរបស់ជនជាប់ចោទឈ្មោះ [redacted] ចំណាប់ ចុះថ្ងៃទី ២៤-០៧-២០១៤ និងឈ្មោះ [redacted] វតនា ចុះថ្ងៃទី ២៤-០៧-២០១៤ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨-០៨-២០១៤ កំបាំងមុខជនជាប់ចោទ ។

ទុកសិទ្ធិទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] , [redacted] | ហត្ថលេខា [redacted] |

ប្រធានសាលាដំបូងខេត្ត...
ប្រធាន

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ០៨ ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]